This project is funded by the European Union

# អង្គការអភិវឌ្ឍន៍ជីវភាពកសិករ

## សហការជាមួយ

# អង្គការទស្សនៈពិភពលោក

## ឧបត្ថម្ភដោយ

# សហភាពអឺរ៉ុប

# ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ តាមគោលការធម្មជាតិ។

# System of Rice Intensification

## គំរោងសកម្មភាពប្រកបដោយនិរន្តភាព ដើម្បីប្រឆាំងភាពក្រីក្រ ភាពស្រេកឃ្លាន និង កង្វះអាហារូបត្ថម្ភ (SAFPHAM) 2010


រៀបរៀងដោយៈ លោក អ៊ុន វី (៨៥៥) ៩៧ ៤៥៦ ២១៣៥

: លោក រាជ ស៊ីដែន (៨៥៥) ៨៩ ៩២២ ០៩៥

: លោក យូរ ណារ៉ុឌ (៨៥៥) ៨៨ ៨៩៤ ០១៨៩

កែសម្រួលដោយ

: លោកស្រី អ៊ុច ភូមី អ្នកគ្រប់គ្រងគំរោង

: លោក ជា កុសល អ្នកគ្រប់គ្រងកម្មវិធី








ទំនាក់ទំនងព័ត៌មាន : លោកស្រី **អ៊ូច តូមី**

: លោក **អ៊ុន វី** (៨៥៥) ៩៧ ៤៥៦ ២១៣៥

: លោក **រាជ ស៊ីដែន** (៨៥៥) ៨៩ ៩២២ ០៩៥

: លោក **យូរ ណាវុធ** (៨៥៥) ៨៨ ៨៩៤ ០១៨៩

អ៊ីម៉ែល : trainingfld@ezecom.com.kh

## មាតិកាអត្ថ

**ចំណងជើងអត្ថបទ** **ទំព័រ**

ជំពូកទី ១ ប្រវត្តិរបស់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ( ប.វ.ស) ------------- ១
ជំពូកទី ២ លក្ខណៈរូបសាស្ត្រ និង មុខងារដំណាំស្រូវ ---------------------------------------- ២
២.១ លក្ខណៈរូបសាស្ត្ររបស់ដំណាំស្រូវ និងមុខងារ ---------------------------------------- ២
២.១.១ ឬស ---------------------------------------------------------------- ២
២.១.២ ដើម---------------------------------------------------------------- ២
២.១.៣ ស្លឹក ---------------------------------------------------------------- ៣
២.១.៤ កួរ ---------------------------------------------------------------- ៣
២.១.៥ ទងកួរមាន ---------------------------------------------------------------- ៣
២.១.៦ គ្រាប់ ---------------------------------------------------------------- ៣
២.២ វដ្តលូតលាស់របស់ដំណាំស្រូវ ----------------------------------------------- ៣
ជំពូកទី៣ បច្ចេកទេសប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ( ប.វ.ស) -------------- ៤
៣.១ គុណសម្បត្តិរបស់ ប.វ.ស ----------------------------------------------- ៤
៣.២ បច្ចេកទេសសំខាន់ៗរបស់ ប.វ.ស----------------------------------------------- ៥
៣.៣ កាជ្រើសរើសគ្រាប់ពូជ ----------------------------------------------- ៧
៣.៤ ការត្រាំ និង ផ្អាប់គ្រាប់ពូជ ----------------------------------------------- ៧
៣.៥ ការជ្រើសរើស និង រៀបចំទីកន្លែងសំរាប់សាប ---------------------------------------- ៨
៣.៦ ការរៀបចំដីស្ទូង ----------------------------------------------- ៩
៣.៧ ការស្ទូងតាមបច្ចេកទេស ប.វ.ស ----------------------------------------------- ១០
៣.៨ ការប្រើប្រាស់ជី----------------------------------------------- ១១
៣.៩ ការកំចាត់ស្មៅ និងការបាចជី ----------------------------------------------- ១២
ជំពូកទី ៤ ការប្រមូលផល ----------------------------------------------- ១៤
៤.១ ការប្រមូលផល ----------------------------------------------- ១៤
៤.២ ការសំអាតគ្រាប់ពូជ----------------------------------------------- ១៤
៤.៣ ការហាល ឬ សំងួតស្រូវ ----------------------------------------------- ១៥
៤.៤ ការទុកដាក់ពូជ ----------------------------------------------- ១៦

## ជំពូកទី ១

## ប្រវត្តិរបស់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ( ប.វ.ស)

ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ(ប.វ.ស)គឺជាការផ្តុំចូលគ្នានូវបច្ចេកទេស ឬការអនុវត្តន៍ល្អៗដើម្បីជួយអោយដំណាំស្រូវលូតលាស់បានល្អនិងផ្តល់ផលច្រើនតាមសក្តានុពលធម្មជាតរបស់វា ។ បានធ្វើការអភិវឌ្ឍន៍ដំបូងនៅប្រទេសម៉ាដាហ្គាស្កា (Madagascar) ក្នុងទស្សវត្សរ៍ឆ្នាំ ១៩៨0 ដោយលោក Henri de Laulanie នៅឆ្នាំ១៩៩៩ ត្រូវបានផ្សព្វផ្សាយដល់ប្រទេសផ្សេងៗ ដោយមានការជ្រោមជ្រែង ពីគំរោងស៊ីអាយអាយអែហ្វអេឌី (CIIFAD) ជាពិសេសពីសាស្ត្រាចារ្យណ័រម៉ាន អាប់ហូស (Norman Uphoff) ។ បច្ចុប្បន្នមានប្រទេសចំនួន២២ បាន និងកំពុងអនុវត្តន៍ ។ ប.វ.ស នេះ បានចាប់ផ្តើមណែនាំចូលមកប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៩៩ ដោយអង្គការ សេដាក់ ហើយពិសោធន៍ជាមួយកសិករតែ២៨គ្រួសារប៉ុណ្ណោះ។ នៅឆ្នាំ ២00៨ នេះ មានកសិករអនុវត្តប្រមាណ ១0៤,៧៥0គ្រួសារក្នុងភូមិ ៤,២៦១ ក្នុងឃុំ៧៩៦ ក្នុងស្រុក១៣៤ ក្នុងខេត្ត-ក្រុង ២៤

# ជំពូកទី ២

# លក្ខណៈរូបសាស្ត្រ និង មុខងារដំណាំស្រូវ

## ២.១ លក្ខណៈរូបសាស្ត្ររបស់ដំណាំស្រូវ និងមុខងារ




**២.១.១ ឬស** : គឺជាផ្នែកមួយរបស់ដើមស្រូវដែលស្ថិតនៅក្នុងដី ។ ឬសមានតួនាទី

- ទ្រទ្រង់ដើមផ្នែកខាងលើ
- ស្រូបយកជីជាតិ និងទឹកពីក្នុងដី រួចបញ្ជូនទៅចិញ្ចឹមដើម និងស្លឹក

**២.១.២ ដើម** : គឺផ្នែកខាងលើដីតភ្ជាប់ពីឬស ទៅស្លឹក និងកួរ ។

មានតួនាទី

- ដឹកនាំជីជាតិ និងទឹកពីឬស ទៅ ចិញ្ចឹមស្លឹក និងកួរ
- ដឹកនាំសារធាតុចិញ្ចឹមពីស្លឹក ទៅឱ្យឬស និងគ្រា

**២.១.៣ ស្លឹក:** មានតួនាទីស្រូបយកឧស្ម័នកាបូនិចនិងថាមពលព្រះអាទិត្យរួមផ្សំនិងទឹកដែលបានមកពីឫស ធ្វើ រស្មីសំយោគ បង្កើតបានសារធាតុចិញ្ចឹម ។

**២.១.៤ កួរ** : គឺជាផ្នែកចុងក្រោយបំផុតនៃចំណុចការលូតលាស់របស់ដើមស្រូវ ។ កួរចែក ចេញជាទងកួរ និងគ្រាប់ (ផ្កា) ។

**២.១.៥ ទងកួរមាន** : ទងកួរមេ និងស្នែង

**២.១.៦ គ្រាប់** : មាន

- សំបកគ្រាប់ធំ, សំបកគ្រាប់តូច, សន្លង់, ទំរគ្រាប់, កន្ទុយ
- គ្រាប់ : គ្រាប់ស្រូវទាំងអស់មានលក្ខណៈខុសៗគ្នាដោយសារទំហំសណ្ឋានទ្រទ្រាយពណ៌សម្បុរ និង ប្រវែងកន្ទុយរបស់វា ។

## ២.២ វគ្គលូតលាស់របស់ដំណាំស្រូវ

មាន ៣ វគ្គ:

១. វគ្គលូតលាស់ មានការប្រែប្រួល (អាស្រ័យទៅតាមពូជ)

២. វគ្គបង្កបង្កើតផល មានរយៈពេល ៣៥ថ្ងៃ

៣. វគ្គទុំ មានរយៈពេល ៣០ថ្ងៃ

### គ្រាហ្វិចតាងរយៈពេលលូតលាស់ដំណាំស្រូវ

IR 66

| វគ្គលូតលាស់ | វគ្គបង្កើតផល | វគ្គទុំ | |
|---|---|---|---|
| ៤០ ថ្ងៃ | ៣៥ ថ្ងៃ | ៣០ ថ្ងៃ | ១០៥ ថ្ងៃ |

IR កេសសរ

| | | | |
|---|---|---|---|
| ៥៥ ថ្ងៃ | ៣៥ ថ្ងៃ | ៣០ ថ្ងៃ | ១២០ ថ្ងៃ |

# ជំពូកទី ៣

## បច្ចេកទេសប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ(ប.វ.ស)

### ៣.១ គុណសម្បត្តិរបស់ ប.វ.ស

កសិករអាចបង្កើនទិន្នផលស្រូវ ២-៣ដង លើសធម្មតា កសិករទទួលប្រាក់ចំណេញច្រើន បន្ថយការចំណាយលើពូជ ជីគីមី ថ្នាំពុល កំលាំងពលកម្មសំរាប់ដកសំណាប និងស្ទូង ។



ដំណាំស្រូវមិនមែនជារុក្ខជាតិទឹកទេតែវាធន់នឹងទឹក ។បើទឹកតិចៗវាលូតលាស់និងបែកគុម្ពបាល្អ ។ស្រូវកាត់បន្ថយសក្តានុពលធម្មជាតិក្នុងការបែកគុម្ពបើស្ទូងសំណាបមានអាយុលើសពី១៥ថ្ងៃឡើងទៅ ។ស្រូវនឹងមានសក្តានុពលបែកគុម្ពខ្ពស់ប្រសិនជាយើងកាត់បន្ថយនូវភាពរន្ធត់របស់វា( ការដកសំណាបរូចបោកការចងសំណាប...)



**ឫសច្រើន ⟷ ដើមច្រើន**

## ៣.២ បច្ចេកទេសសំខាន់ៗរបស់ ប.ទ.ស

- ធ្វើដីស្រែអោយបានរាបស្មើ និងមានប្រព័ន្ធសំរាប់បញ្ចេញបញ្ចូលទឹក
- ជ្រើសរើសគ្រាប់ពូជដែលសុទ្ធ
- រៀបចំសំណាបគោកហើយសាបស្តើងដើម្បីអោយសំណាបថ្លោស( សាបពូជ១គក្រ/ដី៤០ម៉ែត្រការ៉េ)
- ដកថ្នមៗយកតែសំណាបថ្លោសៗ រួចយកទៅស្ទូងភ្លាមៗ
- ស្ទូងសំណាបអាយុខ្ចី យកល្អអាយុតិចជាង១៥ថ្ងៃ ( ១០-១៥ថ្ងៃ)
- ស្ទូងចាប់ស្តើងជាងធម្មតា យកល្អស្ទូងតែ១ដើមៗ
- ប្រសិនបើស្រូវដុះតែឯង នោះវានឹងលូតលាស់បែកគុម្ពតាមសក្តានុពល ធម្មជាតិរបស់វា។
- ដំណាំស្រូវលូតលាស់បានល្អ បើដីធូរមានខ្យល់ចេញចូល និង មានជីជាតិគ្រប់គ្រាន់។

### គោលការណ៍ទាំង ១២ របស់ ប.ទ.ស



## ភាពខុសគ្នារវាងផលិតកម្មស្រូវតាមទំលាប់ និង តាម ប.វ.ស

| តាមទំលាប់ | តាមបច្ចេកទេស ប. វ. ស |
|---|---|
| មិនបានជ្រើសរើសពូជសុទ្ធល្អនិងគ្រាប់ពេញ | ជ្រើសរើសពូជសុទ្ធល្អនិងគ្រាប់ពេញទៅសាប |
| ទុកទឹកច្រើនក្នុងថ្នាល និងសាបក្រាស់ | ថ្នាលគោកដូចរងស្លែ សាបស្តើង |
| ស្ទូងចាប់ធំ សំណាបលាយឡំគ្នាដើមទន់ល្អិត | យកសំណាបថ្លោសៗទៅស្ទូង ស្ទូង១-២ដើម |
| ស្ទូងសំណាបចាស់ អាយុ១ខែឡើង | ស្ទូងសំណាបខ្ចី អាយុតិចជាង១៥ថ្ងៃ |
| ដកបោកសំណាប ចងជាកណ្តាប់ផ្អាប់ ១២ យប់ | ដកថ្នមៗ ដកភ្លាមស្ទូងភ្លាម |
| ស្ទូងញឹក ចន្លោះគុម្ពមិនស្មើគ្នា គ្មានជួរ | ស្ទូងជាជួរបន្ទាត់ រាងរង្វើល |
| មិនបានបន្សុទ្ធពូជមុនពេលច្រូត សំរាប់ទុកពូជ | ធ្វើការបន្សុទ្ធពូជមុនច្រូត និងរក្សាទុកបានល្អ |
| ដកស្មៅមិនទាន់ពេលវេលា មិនញឹកញាប់ | ដកស្មៅញឹកញាប់ទាន់ពេលវេលា ទៀងទាត់ |
| មិនបានប្រើកំទេចកំទីសំរាមដូចជាជីធម្មជាតិពឹងផ្អែកតែជីគីមី | ប្រើជីធម្មជាតិ កំប៉ុស្តគោក និងកំប៉ុស្តទឹកបំប៉ន |
| ទុកទឹកក្នុងស្រែជានិច្ចពេលស្រូវកំពុងលូតលាស់ | ទុកទឹកតិចៗ យកល្អទុកដីសើមៗ |

ស្ទូងតាមទំលាប់កសិករ



ស្ទូងតាមបច្ចេកទេស ប.វ.ស



ស្ទូងតាមទំលាប់កសិករ



ស្ទូងតាមបច្ចេកទេស ប.វ.ស



## ៣.៣ ការជ្រើសរើសគ្រាប់ពូជ

- ពូជសុទ្ធដែលមានគុណភាព(ដំណុះពី៨៥%ឡើងទៅ
- ពូជផ្តល់ទិន្នផលខ្ពស់
- រយៈពេលលូតលាស់ខ្លី( ស្រូវស្រាល ឬស្រូវកណ្តាល)
- ភាពធន់ទ្រាំនឹងការរាំងស្ងួត សត្វល្អិតចង្រៃ និងជំងឺ
- គុណភាពគ្រាប់អង្ករ និងរសជាតិ ពូជសុទ្ធដែលមានគុណភាព(ដំណុះពី៨៥%ឡើងទៅ



## ៣.៤ ការត្រាំ និង ផ្កាប់គ្រាប់ពូជ

- មុនយកគ្រាប់ពូជទៅត្រាំ ត្រូវធ្វើការបណ្តុះសាកជាមុន
- ត្រូវការបរិមាណគ្រាប់ពូជល្អ ១០-១៥គក្រ/ហ.ត
- ច្រកគ្រាប់ក្នុងបាវត្រាំក្នុងទឹកស្អាត២៤ម៉ោង
- យកគ្រាប់ពូជដែលត្រាំរួចលាងអោយស្អាត រួចពង្រាបគ្រាប់ក្នុងបាវអោយ មានកំរាស់ ១០-១៥ស.ម ហើយយកចំបើងគ្របពីលើបាវ
- ត្រូវត្រឡប់បាវស្រូវពីលើមកក្រោមរយៈពេល១២ម៉ោង រួចផ្សើមទឹកតិចៗ




## ៣.៥ ការជ្រើសរើស និង រៀបចំទីកន្លែងសំរាប់សាប

- ងាយស្រួលបញ្ចេញបញ្ចូលទឹក ងាយស្រួលការពារសត្វពាហនៈ និងបក្សី
- ដីថ្នាលត្រូវមានជីជាតិល្អ ស្ថិតនៅឆ្ងាយពីម្លប់រុក្ខជាតិ
- សំរាប់សន្ទូង ១ហិកតា ត្រូវការថ្នាលទំហំ ១៥០-២០០ម៉ែត្រការ៉េ
- ត្រូវដាក់ជីធម្មជាតិ (៣-៥គក្រ/១ម៉ែត្រការ៉េ) រាស់ដីអោយម៉ដ្ឋល្អរួចលើកជារងថ្នាលតូចៗទទឹង ១,៥-២ម៉ែត្រ (ងាយស្រួលសាប ស្រោច ឬបញ្ចេញទឹក បោចស្មៅ និងកំចាត់សត្វល្អិត) បណ្តោយរង ឬ ថ្នាល អាស្រ័យទៅលើស្ថានភាពដី។

**សាបតាមទំលាប់** **សាបតាមបច្ចេកទេស ប.ទ.ស**





## ៣.៦ ការរៀបចំដីស្ទូង

- ចំពោះស្រែប្រាំងឬស្រែប្រដេញទឹកត្រូវភ្ជួររាស់ដីមុនទឹកលិចហើយក្រោយពេលទឹកស្រក គ្រាន់តែរាស់ពង្រាបដី អោយស្មើជាការស្រេច

- ត្រូវភ្ជួរអោយបានច្រើនសារ ជំរៅយ៉ាងតិច១៥ស.ម ហើយរាស់ពង្រាប
- អោយស្មើល្អដើម្បីៈលប់ស្មៅនិងកាកសំណល់រុក្ខជាតិទៅក្នុងដីអោយរលួយជាដី
- អោយដីធូរស្រួលស្ទូង និងប្រព័ន្ធឬសលូតលាស់ល្អ
- ងាយស្រួលគ្រប់គ្រងទឹក
- លប់កប់ជីធម្មជាតិទៅក្នុងដី ដើម្បីកាត់បន្ថយការហើរនៃធាតុចិញ្ចឹម
- បង្កើនរន្ធខ្យល់ក្នុងដី



**ការដកសំណាបតាម ប.វ.ស** **ការដកសំណាបតាមទំលាប់កសិករ**





## ៣.៧ ការស្ទូងតាមបច្ចេកទេស ប.វ.ស

- ស្ទូងថ្មមៗ រាក់ៗ និងកុំអោយបត់ឫសដូចផ្លែសន្ទូច
- ស្ទូងរង្វើលជាងធម្មតាចន្លោះគុម្ព ២០-២៥ ស.ម
- ស្ទូងជាជួរបន្ទាត់ដោយមានចន្លោះគុម្ពស្មើៗគ្នា
- ដកស្មៅ និងបំផុសដីអោយបាន ២-៤ ដង អោយមានខ្យល់ចេញចូល ឫសស្រូវចាក់បានវែង
- ត្រូវអោយមានទឹកតិចៗក្នុងស្រែ ជៀសវាងទឹកច្រើនពេលស្រូវកំពុង លូតលាស់
- ប្រើជីធម្មជាតិអោយបានច្រើន ជាពិសេសជីកំប៉ុស្ត២-៤ត/ហ.ត និងការ

ដាំជីស្រស់បៃតងលើស្រែមុនស្ទូង និងគ្របដីក្រោយស្ទូង

**ការស្ទូងតាមបច្ចេកទេស ប.វ.ស** **ការស្ទូងតាមទំលាប់កសិករ**





## ៣.៨ ការប្រើប្រាស់ជី

គប្បីយកចិត្តទុកដាក់លើការប្រើប្រាស់ជីធម្មជាតិអោយបានខ្លាំងក្លា ព្រោះ

- ធ្វើអោយដីធុសល្អ

-អាចរក្សាសំណើមក្នុងដីបានយូរ

-ជួយបង្កើនជីជាតិដី

- បន្ថយចំណាយក្នុងការទិញជីគីមី និង

- ជួយថែរក្សាបរិស្ថានបានល្អ

- ជីធម្មជាតិដែលត្រូវប្រើមានៈ ជីលាមកសត្វ ជីកំប៉ុស្ត និងជីស្រស់ ( ពួកអំបូរ សណ្តែក ស្នោ ចកអាសូឡា....)

-ចំបើងនិងជញ្ជ្រាំងស្រូវក៏ផ្តល់ជីជាតិសំខាន់ដល់ដីស្រែដែរ ដូច្នេះគួរភ្ជួរ លប់អោយបានល្អ ជៀសវាងការដុតវាចោល

- គួរប្រើជីលាមកសត្វនិងជីកំប៉ុស្តកម្រិត១០-២០ត/ហ.ត ដោយភ្ជួរលប់ នៅពេលភ្ជួរចុងក្រោយបង្អស់

- ចំពោះជីស្រស់និងកាកសំណល់រុក្ខជាតិ ត្រូវភ្ជួរលប់មុនស្ទូង១០-១៥ថ្ងៃ អោយរលួយបានល្អ





### ជីស្រស់

ចក



សណ្តែក



កំប្លោក



## ៣.៩ ការគ្រប់គ្រងទឹក

- ថែទាំភ្លឺស្រែអោយបានល្អ តែកុំទុកទឹកច្រើនពេកនៅពេលដំណាំស្ថិតក្នុង វគ្គលូតលាស់ជាពិសេសដំណាក់កាលបែកគុម្ព

- កំចាត់ស្មៅអោយអស់ពីស្រែ ព្រោះវាជាគូរប្រជែងរបស់ស្រូវ

- ក្រោយស្ទូងរួចត្រូវរក្សាទឹកក្នុងស្រែមិនអោយលើសពី ២-៣ ស.ម ឬម្តងស្ងួតម្តងសើម ឬគ្រាន់តែសើមតិចៗបានហើយ  ដើម្បីៈ

- បង្អាក់ការលូតលាស់របស់ស្មៅ

- ជួយដំណាំស្រូវស្រូបយកជីជាតិពីដី

-ជួយរំលាយសារធាតុសរីរាង្គ

-ធ្វើអោយដំណាំស្រូវបែកគុម្ពបានច្រើន

(បើអាចធ្វើបាន គួរជីកស្រះក្នុងស្រែទំហំ ២០ម x ១០ម សំរាប់ផ្ទុកទឹក និង ចិញ្ចឹមត្រី)

**ការគ្រប់គ្រងទឹកតាមបច្ចេកទេស ប.ទ.ស**



**ការគ្រប់គ្រងទឹកតាមទំលាប់កសិករ**



## ៣.៩ ការកំចាត់ស្មៅ និងការបាចជី

-ត្រូវដកស្មៅអោយស្អាត ព្រោះវាដណ្តើមពីស្រូវនូវសារធាតុចិញ្ចឹម សំណើម ពន្លឺ និងជាជំរកសត្វចង្រៃ និងកណ្តុរ

- អាចបាចជីកំប៉ុស្តដែលរលួយល្អនៅដំណាក់កាលបែកគុម្ព ដើម្បីបង្កើនការ បែកគុម្ព ជាអតិបរមា និងបាចម្តងទៀតនៅពេលចាប់ផ្តើមពន្លកកួរ ដើម្បី អោយមានកួរវែង ហើយគ្រាប់ច្រើនថ្លោសល្អ





ទិដ្ឋភាពដំណាំស្រូវនៅដំណាក់កាលទុំ





# ជំពូកទី ៤

# ការប្រមូលផល

## ៤.១ ការប្រមូលផល

- ច្រូតកាត់អោយទាន់ពេលវេលាជៀសវាងការបាត់បង់ផល

-ត្រូវច្រូតនៅពេលសង្កេតឃើញគ្រាប់ស្រូវ៨០-៨៥%នៅចុងកួរពណ៌ លឿងដូចចំបើងហើយគ្រាប់គល់កួរដាក់ម្សៅ





## ៤.២ ការសំអាតគ្រាប់ពូជ

ដើម្បីញែកគ្រាប់ពេញ និងគ្រាប់តូចស្កៀតឬសំដីស្រូវចេញត្រូវអនុវត្តន៏ៈ

- ត្រាំគ្រាប់ពូជក្នុងទឹកអំបិល១ធុង( អំបិល១ក្តាប់/ទឹក១ធុង) កូរអោយ សព្វ រួចស្រង់គ្រាប់ដែលមិនពេញល្អចេញ( គ្រាប់ដែលអណ្តែត)
- តាមបទពិសោធន៏អាចយកគ្រាប់ពូជត្រាំក្នុងទឹកស្តៅ( សំបក ស្លឹក ឬ គ្រាប់ស្តៅ) អោយស្រូវលូតលាស់ល្អ និងការពារសត្វល្អិត
- ត្រូវស្រង់គ្រាប់ដែលល្អទៅលាងទឹកអោយស្អាតមុនយកទៅត្រាំសាប



## ៤.៣ ការហាល ឬ សំងួតស្រូវ

-គ្រាប់ស្រូវទើបបោកបែនរួចមានសំណើម ១៨-២៥% បើយកទៅទុក ដាក់ភ្លាម ធ្វើអោយគ្រាប់ស្រូវពុកផុយដោយសារពួកផ្សិត និងមានសត្វល្អិតចង្រៃបំផ្លាញ

-មុនទុកដាក់ត្រូវហាល ២-៣ថ្ងៃ(សំណើម១៤%)

-ជៀសវាងការហាលស្ងួតជ្រុល ព្រោះបណ្តាលអោយប្រេះគ្រាប់ និងបាក់គ្រាប់អង្ករពេលកិន





## ៤.៤ ការទុកដាក់ពូជ

-ត្រូវទុកអោយស្រូវទុំល្អក្នុងស្រែយ៉ាងហោចណាស់ ៩0%

-ហាលអោយដល់សំណើម១៤%( ពេលខាំគ្រាប់ស្រូវបាក់ស្មើគ្នា ផ្ទៃកកណ្តាល ពណិថ្លា)

-ត្រូវច្រកក្នុងថង់ប្លាស្ទិករួចដាក់ក្នុងបាវចងមាត់អោយជិត និងមានសរសេរ ឈ្មោះពូជ ថ្ងៃខែច្រូត...

-រក្សាទុកនៅកន្លែងស្ងួតគ្មានពន្លឺថ្ងៃចាំងចូល ប៉ះនឹងសំណើម ហើយមាន ខ្យល់ចេញចូលគ្រប់គ្រាន់

**ការទុកដាក់ពូជលក្ខណៈបែបពានិជ្ជកម្ម** **ការទុកដាក់ពូជតាមធំលាប់កសិករ**





**ការទុកដាក់ស្រូវសំរាប់ទុកពូជ**





## ៤.៥ ការសន្សំជីធម្មជាតិ (កំប៉ុស្ត)



# សូមអរគុណ